# វប្បធម៌ អាល់ហ្សូបារ៉ា (Culture of Al Zubarah )

អាល់ហ្សូបារ៉ា (Al Zubarah ) គឺជាស្ថានីបុរាណវិទ្យា និងជាទីតាំងវប្បធម៌មួយនៅក្នុងប្រទេសកាតា ដែលមានចម្ងាយប្រមាណជាង ៨៥គីឡូ ពីរាជធានីដូហា (Doha)។ ស្ថានីយបុរាណវិទ្យាមួយនេះ ជាបណ្តុំ វប្បធម៌ នយោបាយ ហើយក៏ជា កំពង់ផែ សម្រាប់ការជួញដូរពាណិជ្ជកម្មដ៏សំខាន់នៅក្នុងតំបន់ឈូងសមុទ្រពែក្ស នៅចន្លោះស.វ.ទី១៨ និងទី២០ ជាពិសេសការជួញដូរ គុជខ្យង( Pearl trading)។[១]

ទីតាំងនៃស្ថានីយបុរាណវិទ្យា អាល់ហ្សូបារ៉ា ត្រូវបានកំណាយដំបូងនៅដើមឆ្នាំ ១៩៨០ ដោយក្រុមបុរាណវិទ្យាកាតា។ អំឡុងពេលនោះ គេបានរកឃើញសំណង់ជាបន្ទប់តូចៗជាច្រើននៅខាងត្បូងនៃតំបន់ស្ថានីយ។ ក្រោយមកការស្រាវជ្រាវថ្មីៗជាច្រើន បានចាប់ផ្តើមពីឆ្នាំ២០១៤ ដោយក្រុមអ្នកស្រាវជ្រាវជាតិ កាតា និងអន្តរជាតិ បានសិក្សានៅទីតាំងច្រើនកន្លែង និងបានបង្ហាញពីទិន្នន័យដ៏សំខាន់ពីការស្រាវជ្រាវនេះ ក្នុងតំបន់ អាល់ហ្សូបារ៉ា គឺជាតំបន់បែងចែកជាបីផ្នែកផ្សេងគ្នា ដែលផ្នែកធំជាងគេ គឺជាទីក្រុង រួមមាន សំណង់ព្រះវិហារ វាំង និង កំពង់ផែ សម្រាប់តភ្ជាប់ពីមហាសមុទ្រឥណ្ឌា អារ៉ាប់ និងអាស៊ីខាងលិច។[២] តាមរយៈទិន្នន័យបុរាណវិទ្យា បានបង្ហាញថា ទីក្រុងនេះត្រូវបានកសាងនៅស.វ.ទី១៨ ពោល ក្នុងឆ្នាំ១៧៦០គ.ស.។ ផ្នែកទីពីរ គឺជាកំពែងដែលព័ទ្ធជុំវិញក្រុងហៅថា តំបន់ Qal’at Murair និងចុងក្រោយជាបន្ទាយ ( Al Zubarah fort) ដែលកសាងនៅឆ្នាំ១៩៣៨។[៣]

បន្ទាប់ពីកំណាយនៅទីតាំងស្ថានីយនេះរួច អ្នកស្រាវជ្រាវបានដឹងថាទីតាំងស្ថានីយនេះជាទីតាំងដ៏សំខាន់ជាងគេនៅក្នុងប្រទេសកាតា ដោយបានរកឃើញនូវភស្តុតាង

[១] Al Zubarah Archaeological Site - UNESCO World Heritage Centre

[២] *Ibid*

[៣] Al Zubarah: Qatar’s Largest Heritage Site - Qatar Museums (qm.org.qa)

អត្ថបទដោយ៖ អេង តុលា

សំខាន់ជាច្រើនដូចជា កុលាលភាជន៍ជាច្រើន ដែលមានប្រភពមកពី ចិន អាហ្វ្រិក ឥណ្ឌា និងជាពិសេសគុជខ្យង។[៤]

គួរបញ្ជាក់ដែរថា ទីក្រុងនៃ តំបន់អាល់ហ្សូបារ៉ា ត្រូវបានបោះបង់ចោលអស់រយៈពេលជាង ២០០ឆ្នាំ ប៉ុន្តែសំណង់ស្ថាបត្យកម្មនៅទីនោះ នៅល្អប្រសើរច្រើន។ ស្ថានីយបុរាណវិទ្យាផ្សេងទៀត ក្នុងប្រទេសកាតា គឺភាគច្រើនជាសមុទ្រខ្សាច់។ រីឯសំណង់ កំពែង Qal at Murair វិញដែលមានរាងជាចតុកោណព័ទ្ធជុំវិញក្រុង ដែលតាមរយៈការធ្វើកំណាយបុរាណវិទ្យាបានរកឃើញនូវសំណង់ផ្ទះ សំណល់គ្រឹះព្រះវិហារនៅក្បែរនោះ ដោយអ្នកស្រាវជ្រាវសង្ឃឹមថា និងបន្តរកឃើញសំណង់ផ្សេងៗ ជាបន្តបន្ទាប់ទៀត ដោយសារសំណង់ភាគច្រើនត្រូវបានកប់ក្នុងខ្សាច់។ ចំណែកបន្ទាយ ( Al Zubarah fort) ត្រូវបានកសាងនៅអំឡុងឆ្នាំ១៩៣៨ ដោយ ស្តេច Sheikh Abdullah bin Jassim Al Thani ដើម្បីការពារតំបន់ខាងជើងនៃឈូងសមុទ្រពែក្ស។ សំណង់នៃបន្ទាយនេះមានទម្រង់រាងការ៉េ ដោយមានកំពែងខ្ពស់ពីឥដ្ឋ និងមានតួប៉ម ៤ នៅគ្រប់ទិស។ រហូតដល់ឆ្នាំ ១៩៨៦ ទីនេះ នៅតែបន្តប្រើប្រាស់ជាមូលដ្ឋានទ័ព និងប៉ូលីសក្នុងតំបន់នេះ និងមកបច្ចុប្បន្នទីតាំងបន្ទាយនេះបានក្លាយជាសំណង់បេតិកភណ្ឌ និងសារមន្ទីរប្រវត្តិសាស្ត្រក្នុងតំបន់។

សរុបតាមរយៈទិន្នន័យបុរាណវិទ្យាជាច្រើន បានបង្ហាញថា តំបន់ស្ថានីយអាល់ហ្សូបារ៉ា គឺជាមជ្ឈមណ្ឌលវប្បធម៌ នយោបាយ និងតំបន់ពាណិជ្ជកម្មដ៏សំខាន់នៅក្នុងតំបន់សមុទ្រពែក្ស លើការ ដូញដូរ រ៉ែ ប្រេងឆៅ និងគ្រឿងបរិភោគផ្សេង ដែលចាប់ពីស.វ.ទី ១៨ រហូតដល់ស.វ.ទី ២០។

---

៤ https://www.jstor.org/stable/41623647

អត្ថបទដោយ៖ អេង តុលា




រូបលេខ១-២៖ ផែនទីបង្ហាញពីទីតាំងនៃស្ថានីយ៍ អាល់ហ្សូបារ៉ា និងសំណង់ដែលហៅថា ជាទីក្រុង
ប្រភព៖ UNESCO



អត្ថបទដោយ៖ អេង តុលា



រូបលេខ២៣ ៖ កុលាលភាជន៍ដែលរកឃើញនៅក្នុងបន្ទប់តូចមួយ និង រូបទី២៤ ៖ កំពែងក្រុងបុរាណ
ប្រភព៖ UNESCO



រូបលេខ២៤ ៖ កំពែងក្រុងបុរាណ
ប្រភព៖ UNESCO

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥ ៖ កុលាលភាជន៍ចិន និងឥណ្ឌា

ប្រភព៖ [Al Zubarah: Qatar’s Largest Heritage Site - Qatar Museums (qm.org.qa)]



រូបលេខ២៦ ៖ គុជខ្យងដែលរកឃើញនៅក្នុងរណ្ដៅកំណាយ

ប្រភព៖ [Al Zubarah: Qatar’s Largest Heritage Site - Qatar Museums (qm.org.qa)]




អត្ថបទដោយ៖ អេង តុលា

## ឯកសារយោង


Al Zubarah Archaeological Site - UNESCO World Heritage Centre

Al Zubarah: Qatar’s Largest Heritage Site - Qatar Museums (qm.org.qa)

Al Zubarah Archaeological Site: Information Booklet (english) (windows.net)

https://www.jstor.org/stable/41623647


អត្ថបទដោយ៖ អេង តុលា